# ខ្លឹមសារសង្ខេប
# ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ( UNHRC )
# បណ្តឹងលេខ១១១០/២០០២

**១.ពាក្យគន្លឹះ៖** ទោសប្រហារជីវិត, សិទ្ធិទទួលបានជំនួយផ្លូវច្បាប់, ការត្រួតពិនិត្យដោយតុលាការខ្ពស់, ការវិនិច្ឆ័យសេចក្តីដោយអព្យាក្រឹត្យ

**២. នីតិវិធី៖** អ្នកប្តឹងជាជនជាតិហ្វីលីពីន គាត់ត្រូវបានឃាត់ខ្លួនចំនួនពីរដង ពីបទរំលោភកូនស្រីចុងរបស់ខ្លួន។ លើកទីមួយ ត្រូវបានដោះលែងមកវិញ។ ក្នុងការឃាត់ខ្លួនទាំងពីរលើក គាត់អះអាងថា គ្មានដីកា មិនមានការប្រាប់ពីបទចោទ និងមិនទទួលបានជំនួយផ្លូវច្បាប់ (មេធាវី) ទេ។ គាត់ត្រូវបានសម្រេច កាត់ទោសប្រហារជីវិត។ គាត់ បានប្តឹងទៅតុលាការកំពូល ហើយតុលាការនេះ បានសម្រេចតម្កល់សាលក្រមប្រហារជីវិត។ គាត់អះអាងថា តុលាការកំពូល មិនបានពិនិត្យមើលសក្ខីកម្មរបស់ជនរងគ្រោះជាថ្មី ដែលគាត់គិតថា ទាំងសាលាជាន់ទាប បានប្រព្រឹត្តខុស ដោយសារជឿតែទៅលើសក្ខីកម្មរបស់ជនរងគ្រោះក្នុងដាក់ទោសគាត់។ គាត់ត្រូវបានជូនដំណឹងតែ ៨ ម៉ោងមុននឹងប្រហារជីវិត ដែលគាត់មិនបានជួបគ្រួសារជាលើកចុងក្រោយ (កថាខ័ណ្ឌទី៤.២)។

ផ្អែកតាមអង្គហេតុនេះ គាត់អះអាងថា ហ្វីលីពីនដែលជារដ្ឋភាគី បានបំពានមាត្រា៩(១) មាត្រា១៤(១), (២), មាត្រា៦ មាត្រា៧ និងមាត្រា១០(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

## ៣. សំអាងហេតុ និងសេចក្តីសម្រេច៖

**ក.** ផ្អែកតាមអង្គហេតុដែលបានឯកភាព អ្នកប្តឹងត្រូវបានចោទ និងដាក់ទោសប្រហារជីវិតជាស្វ័យប្រវត្តិ ដោយគ្មានពិចារណានូវស្ថានភាពបុគ្គល...នេះនាំឲ្យបំពានមាត្រា៦(១) ដែលហាមឃាត់ទោសប្រហារជីវិត។

**ខ.** ច្បាប់ប្រទេសហ្វីលីពីន ក្រោយពីមានសាលក្រមប្រហារជីវិត មានរយៈពេលមិនតិចជាង ១៨ ខែ ដើម្បីស្នើសុំឲ្យប្រធានាធិបតីលើកលែងទោស។ តាមព័ត៌មានក្នុងសំណុំរឿង វាហាក់ដូចជាមិនពិតតាមអ្វីដែលអ្នកប្តឹង បានអះអាង ដូចនេះ គណៈកម្មាធិការ មិនបានរកឃើញថា ហ្វីលីពីន បានបំពានមាត្រា៧ និងមាត្រា១០(១)ទេ។

**គ.** ផ្អែកតាមអង្គហេតុដែលបានឯកភាព អ្នកប្តឹងមិនទទួលបានជំនួយផ្នែកច្បាប់ (ក្នុងពេលឃុំខ្លួនពីរលើក) ត្រូវបានប្រាប់ពីបទចោទ ដែលនេះនាំឲ្យមានការបំពានមាត្រា១៤(៣.ឃ) និងមាត្រា៩(១.២.៣)។

**៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)**

*គណៈកម្មាធិការ រំលឹកដល់យុត្តិសាស្ត្ររបស់ខ្លួនថា ការដាក់ទោសប្រហារជីវិតជាកំហិត និងស្វ័យប្រវត្តិ បង្កើតជាការដកហូតជីវិតដោយបំពារបំពាន ផ្ទុយនឹងមាត្រា៦(១) នៃកតិកាសញ្ញា ក្នុងស្ថានភាពដែលទោសប្រហារជីវិត ត្រូវបានដាក់ ដោយមិនបានពិចារណានូវស្ថានភាពបុគ្គល ឬស្ថានភាពនៃបទល្មើស* (កថាខ័ណ្ឌទី៥.២)។

*គណៈកម្មាធិការ រំលឹកឡើងវិញនូវយុត្តិសាស្ត្ររបស់ខ្លួន ដែលថា ការចេញដីកាប្រហារជីវិត នាំឲ្យមានតានតឹងផ្លូវចិត្តដល់បុគ្គលពាក់ព័ន្ធ និងយល់ថា រដ្ឋភាគី គួរព្យាយាមកាត់បន្ថយ នូវភាពតានតឹង* (anguish) *នោះ ជាអប្បបរិមាតាមតែអាចធ្វើទៅបាន* (កថាខ័ណ្ឌទី ៥.៤)។

ទស្សនៈទាំងស្រុងសូមមើល៖ [CCPR/C/82/D/1110/2002, Rolando v. the Philippines]